ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**សូមគោរពជូន**
**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**
**និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**តាមរយៈ:** - ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.បជ
- លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**កម្មវត្ថុ:** របាយការណ៍ស្តីពីលទ្ធផល នៃការចូលរួមកិច្ចប្រជុំឆ្លងកាត់ព្រំដែនដើម្បីពង្រឹងកិច្ចសហការផ្នែកសុខភាពជនទេសន្តរប្រវេសន៍រវាងព្រះរាជាណាចក្រថៃ ព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋប្រជាមានិតឡាវ ។

**យោង:** - លិខិតលេខ ២៣/៣៧០/IOM ចុះថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០២៣ របស់អង្គការ IOM ។
- ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ លើលិខិតលេខ៤៤២៩/២៣ សណ របស់ គ.ជ.ប.ជ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពរាយការណ៍ជូន **លោកជំទាវ** អំពីលទ្ធផលនៃកិច្ចប្រជុំនេះដូចខាងក្រោម៖

**<u>សមាសភាពអ្នកចូលរួម សរុប ៨០</u>**នាក់ (ស្រី ២៦នាក់)

**១.ភាគីកម្ពុជាចំនួន១៣នាក់ (ស្រី ៤នាក់) មកពី ៖**

-ក្រសួងសុខាភិបាលចំនួន ០៥រូប
-អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចំនួន ០២រូប
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ០២រូប
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទាចំនួន ០២រូប
-អង្គការ IOM កម្ពុជាចំនួន ០២រូប។

**២.ភាគីថៃចំនួន៥២នាក់ (ស្រី១៨នាក់) មកពី៖**

-នាយកដ្ឋានការងារ
-ការិយាល័យអធិការកិច្ចMOPH
-ការិយាល័យគ្រប់គ្រង និងបង្ការជំងឺតំបន់ទី១០ នៃខេត្តអ៊ូប៊ុនរាជថានី
-ផ្នែករដ្ឋបាល នៃក្រសួងសុខាភិបាល
-ការិយាល័យអន្តោប្រវេសន៍
-ផ្នែកជានាវ៉ាប់រងសុខភាព និងសេដ្ឋកិច្ច
-ក្រសួងការបរទេស ក្រសួងមហាផ្ទៃ

ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍

-ការិយាល័យសុខាភិបាលខេត្តអ៊ូប៊ុនរាជថានី
-ការិយាល័យការងារខេត្តអ៊ូប៊ុនរាជថានី
-ការិយាល័យស ស យ ក ខេត្តអ៊ូប៊ុន
-នគរបាលអន្តោប្រវេសន៍ខេត្តអ៊ូប៊ុន។

៣.ភាគីឡាវចំនួន១៥នាក់(ស្រី៦នាក់) មកពីៈ

-នាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ
-ការិយាល័យជានារ៉ាប់រងសុខភាពជាតិ
-នាយកដ្ឋានគ្រប់គ្រងការងារ
-ក្រសួងសន្តិសុខសាធារណ:(នាយកដ្ឋានអន្តោប្រវេសន៍)
-ក្រសួងការងារ និងសុខមាលភាពសង្គម (MLSW នាយកដ្ឋានលើកកម្ពស់ការងារ)
-ក្រសួងការបរទេស (នាយកដ្ឋានអង្គការអន្តរជាតិ)សុវណ្ណខេត្ត សាយបូលី និងចំប៉ាសាក់
-មន្ទីសុខាភិបាលខេត្តចំប៉ាសាក់
-មន្ត្រីអន្តោប្រវេសន៍ខេត្តចំប៉ាសាក់
-មន្ទីរត្រួតពិនិត្យជំងឺឆ្លង
-នាយកដ្ឋានថែទាំសុខភាព និងស្ថានីតិសម្បទាខេត្ត (LSW)។

## គោលបំណងនៃកិច្ចប្រជុំ

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកសុខភាពជនចំណាកស្រុក ក្នុងចំណោមប្រទេសជិតខាង កម្ពុជា ឡាវ និងប្រទេសថៃ ជម្រុញការផ្លាស់ប្តូរព័ត៌មានស្តីពីធនធានថែទាំសុខភាព និងពិចារណាលើការបង្កើតពិធីសារសេវាថែទាំសុខភាពឆ្លងព្រំដែន ដើម្បីធានាបាននូវការចូលប្រើប្រាស់សេវាសុខភាពតាមទូរស័ព្ទចល័តដោយរលូន និងចំនួនជនចំណាកស្រុកតាមផ្លូវធ្វើចំណាកស្រុករបស់ពួកគេក្នុងនោះដោយផ្តោតលើចំនុចអាទិភាពសំខាន់ៗចំនួន ៤រួមមានៈ

១. ដើម្បីរំលេចបទពិសោធន៍របស់ប្រទេសនិមួយៗ ចែករំលែកមេរៀនដែលបានរៀន និងការអនុវត្តដ៏ល្អបំផុតដើម្បីអនុវត្តន៏កម្មវិធីសុខភាពចំណាកស្រុក។
២. ដើម្បីផ្តល់នូវការយល់ដឹងកាន់តែច្បាស់អំពីគំរូនៃការធ្វើចំណាកស្រុករបស់ប្រជាជនចំណាកស្រុកមកពីប្រទេសជិតខាង។
៣. ដើម្បីពិភាក្សាជាមួយប្រទេសជិតខាងអំពីវិធានការដែលមានសក្តានុពលក្នុងការកាត់បន្ថយហានិភ័យសុខភាពនៃជនចំណាកស្រុក។
៤. ដើម្បីពិភាក្សាអំពីផែនការសកម្មភាពរួមគ្នាសម្រាប់ការបង្កើនលទ្ធភាពទទួលបានសុខភាពក្នុងចំណោមជនចំណាកស្រុក និងចល័តចំនួនប្រជាជន។

## លទ្ធផលនៃកិច្ចប្រជុំ

ជាលទ្ធផលនៃកិច្ចប្រជុំភាគីទាំងបីបានឯកភាពលើចំនុច៤សំខាន់ៗរួមមានៈ

១. គោលនយោបាយ និងទិសដៅអនុវត្តដែលបានពិភាក្សាក្នុងចំណោមភាគីទាំងអស់ ដើម្បីជំរុញអោយមានប្រសិទ្ធភាព ការអនុវត្តកម្មវិធីសុខភាពចំណាកស្រុក។

២. ការផ្លាស់ប្តូរបទពិសោធន៍សិក្សា និងសមិទ្ធិផលប្រតិបត្តិការលើសុខភាពជនចំណាកស្រុក។
៣. ស្វែងរកឱកាសសម្រាប់កិច្ចសហប្រតិបត្តិការឆ្លងព្រំដែន ដើម្បីធ្វើការពិនិត្យសុខភាពនៅតាមព្រំដែន និងចំណុចឆ្លងកាត់ ធានាការចូលប្រើប្រាស់ និងការបន្តការថែទាំ។
៤. ការរក្សាការដឹកនាំ និងការប្តេជ្ញាចិត្តផ្នែកនយោបាយខណៈពេលដែលការកសាងសន្ទុះសម្រាប់ជនចំណាកស្រុកសម្រាប់គោលនយោបាយមិត្តភាព។

មុនពេលបញ្ចប់ការបិទកិច្ចប្រជុំ **ឯកឧត្តម ម៉ៅ តាន់អ៊ាន** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល តំណាងភាគីកម្ពុជាបានមានមតិផ្តាំផ្ញើចំពោះអង្គពិធី និងបានវាយតម្លៃខ្ពស់លើកិច្ចប្រជុំនេះនិងថ្លែងអំណរគុណដល់គ្រប់ភាគីដែលចូលរួមប្រជុំ និងកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កា និងជូនពរដល់អង្គពិធីទាំងអស់ឱ្យជួបតែសេចក្តីសុខ ទទួលបានជោគជ័យគ្រប់ភារកិច្ច និងបានប្រកាសបិទកម្មវិធីនៅវេលាម៉ោង ១២:០០នាទី ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៣។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ ។

សូម **លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ថ្ងៃ..អង្គារ..៦..រោច..ខែ..មិគសិរ..ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី..០២..ខែ..មករា..... ឆ្នាំ២០២៤

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ឯក **ហ៊ិន ស៊ីនាទ**

បានឃើញ និងគោរពជូន

**លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ**

**គ.ជ.ប.ជ** មេត្តាពិនិត្យ និងជ្រាបជារបាយការណ៍។

ថ្ងៃ..សុក្រ..៩..រោច..ខែ..មិគសិរ..ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី..០៥...ខែ..មករា.....ឆ្នាំ២០២៤

**អគ្គលេខាធិការរង**

ឧត្តមសេនីយ៍ឯក ខៀវ ចាន់រ៉ា

បានឃើញ និងសូមគោរពជូន

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាពិនិត្យ និងជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

ថ្ងៃ..ចន្ទ..១២..រោច..ខែ..មិគសិរ..ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី..០៨...ខែ..មករា....ឆ្នាំ២០២៤

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ. ប៊ុណ្ណ សំខាន់

បានឃើញ
08/01/24

ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍